# ស្ថានភាពទី ១ ៖ រ៉ូជើ—តើមានអ្វីអាចជួយខ្ញុំឲ្យឆ្លងកាត់គ្រាលំបាកបាន ? ( ម៉ាថាយ ១៤:១៣–២៣ )

សៀវភៅសិក្សាព្រះគម្ពីរសញ្ញាថ្មីសម្រាប់ថ្នាក់សិក្ខាសាលា

នៅក្នុង ម៉ាថាយ ១៤:១–១២ យើងដឹងថា ស្ដេចហេរ៉ូឌ បានកាត់ក្បាល យ៉ូហាន-បាទីស្ទ ។ សូមស្រមៃពីការរំជួលព្រះទ័យរបស់ព្រះយេស៊ូវ នៅពេលទ្រង់បានឮថាមិត្តភក្ដិ និងបងប្អូនជីដូនមួយរបស់ទ្រង់ត្រូវបានគេសម្លាប់នោះ ។

សិក្សាពីអ្វីដែលព្រះអង្គសង្គ្រោះបានធ្វើនៅក្នុង ម៉ាថាយ ១៤:១៣–២៣ ដោយរកមើល និងគូសចំណាំភស្ដុតាងនៃគោលការណ៍នេះ ៖ **យើងអាចធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទដោយបង្ហាញព្រះហឫទ័យក្ដួលអាណិត និងការបម្រើអ្នកដទៃ ទោះបីយើងកំពុងជួបការលំបាកផ្ទាល់ខ្លួនក៏ដោយ** ។ សូមកំណត់ចំណាំថា « ទីរហោស្ថាន » ( ខទី ១៣ ) គឺជាកន្លែងដែលស្ងាត់ដាច់ស្រយាលពីគេ ហើយ « ស្បៀងអាហារ » ( ខទី ១៥ ) មានន័យថា « អាហារ » ។

- តើអ្នករកឃើញអ្វីខ្លះនៅក្នុងខគម្ពីរទាំងនេះ ដែល គាំទ្រ ដល់ គោលការណ៍ នេះ ?
- តើ ព្រះយេស៊ូវបាន ធ្វើអ្វីខ្លះ សូម្បី តែ បន្ទាប់ពីដឹងថា យ៉ូហាន-បាទីស្ទ ត្រូវបាន គេ សម្លាប់នោះ ?
- តើ គំរូ របស់ ព្រះអម្ចាស់ អំពី ការបម្រើ ដោយ មិនគិត ពីខ្លួនព្រះអង្គផ្ទាល់ ជួយ នរណាម្នាក់ដែលកំពុង ជួប ការលំបាកយ៉ាងដូចម្ដេច ?

អែលឌើរ ដេវីឌ អេបែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនពីរបៀបដែលយើងអាចអភិវឌ្ឍបុគ្គលិក លក្ខណៈ ដូច ព្រះគ្រីស្ទ ៖



ឧទាហរណ៍ បុគ្គលិក លក្ខណៈនោះត្រូវបានបើកសម្ដែងនៅក្នុងអំណាចដើម្បីញែកដឹងអំពីការរងទុក្ខរបស់មនុស្សដទៃ ពេលយើងខ្លួនឯងកំពុងរងទុក្ខ នៅក្នុងសមត្ថភាពដើម្បីដឹងអំពីភាពស្រេកឃ្លានរបស់មនុស្សដទៃ ពេលយើងស្រេកឃ្លាន និងនៅក្នុងអំណាចឈោងទៅជួយ និងផ្ដល់ក្ដីមេត្តាដល់ការឈឺចាប់ខាងវិញ្ញាណរបស់មនុស្សដទៃ ពេលយើងកំពុងឈឺចាប់ខាងវិញ្ញាណរបស់យើងផ្ទាល់ ។ ដូច្នេះបុគ្គលិក លក្ខណៈនេះត្រូវបានបង្ហាញឡើងតាមរយៈការមើល ការងាក និងការឈោងទៅជួយ នៅពេលការឆ្លើយតបតាមសភាវគតិរបស់មនុស្សខាងសាច់ឈាមដែលយើងម្នាក់ៗមាន គឺការធ្វើតាមចំណង់ចិត្តរបស់ខ្លួន ហើយមានចិត្តអាត្មានិយម និងគិតតែពីខ្លួនឯង ។...

... ប្រាកដណាស់ ក្នុងជីវិតរមែងស្លាប់នេះយើងអាចធ្វើបាន យើងអាចព្យាយាមដោយក្ដីសុចរិតដើម្បីទទួលបាននូវអំណោយទានខាងវិញ្ញាណ ដែលទាក់ទងនឹងសមត្ថភាព ដើម្បីឈោងទៅជួយ និងឆ្លើយតបយ៉ាងសមរម្យទៅកាន់មនុស្សដទៃដែលកំពុងជួបនូវឧបសគ្គ ឬទុក្ខវេទនា ដែលមានឥទ្ធិពលលើយើងភ្លាមៗ និងខ្លាំងក្លា ។

យើងពុំអាចទទួលបានសមត្ថភាពបែបនោះតាមរយៈអំណាចឆន្ទៈសុទ្ធសាធ ឬការប្ដេជ្ញាចិត្តផ្ទាល់ខ្លួនយើងឡើយ ។ ផ្ទុយទៅវិញ យើងត្រូវការ និងពឹងផ្អែកទៅលើ « បុណ្យគុណ និងសេចក្ដីមេត្តាករុណា និងព្រះគុណនៃព្រះមែស៊ីដ៏បរិសុទ្ធ » ( នីហ្វៃ ទី២ ២:៨ ) ។ ( ដេវីដ អេ បែដណា បានដកស្រង់សម្ដី សារ៉ា ជេន វីវើរ « Elder Bednar Addresses ‘the Character of Christ’ during ២០១៩ Mission Leadership Seminar » *Church News* ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៩ )

នៅពេលអ្នករៀបចំចែកចាយនូវអ្វីដែលអ្នកបានរៀន សូមសញ្ជឹងគិតអំពីបទពិសោធន៍ដែលអ្នកបានបម្រើដល់អ្នកដទៃ ។

- ហេតុអ្វីអ្នកគិតថា ការបម្រើដូចជាព្រះគ្រីស្ទអាចជួយយើងក្នុងគ្រាដែលយើងជួបឧបសគ្គផ្ទាល់ខ្លួនដែរនោះ ?

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ២០២២ by Intellectual Reserve, Inc. All rights reserved. កំណែ ៖ ២/២១ ។ ការបកប្រែនៃ *Scenario 1: Roger* ។
Cambodian ។ PD60012661 258. Printed in the United States of America.